ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ៣១/១០-ព្រែកព្រែង ត្រេឌីង

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ អ៊ឹង សុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ សុង វណ្ណស៊ីន

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ គង់ ផល្លះ

## ភាគីវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ព្រែកព្រែង ត្រេឌីង (កម្ពុជា)

អាសយដ្ឋាន : ភូមិព្រែកព្រែង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ : ០៩២ ៨១៨ ៥៣៤ ទូរសារ : គ្មាន

តំណាងភាគីនិយោជក : អវត្តមាន

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សហព័ន្ធសហជីពយុវជនខ្មែរ

- សហជីពយុវជនខ្មែរ នៃក្រុមហ៊ុន ព្រែកព្រែង ត្រេឌីង (កម្ពុជា)

អាសយដ្ឋាន : ភូមិព្រែកព្រែង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល

លេខទូរស័ព្ទ : ០១២ ៩០៧ ៩០២ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិតៈ អវត្តមាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤

No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824

E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

# បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនធ្វើកិច្ចសន្យាការងារជាមួយកម្មកររយៈពេល ០៦ ខែ ទៅ ០១ ឆ្នាំ ។

២- នៅពេលកម្មករឈប់សម្រាកមាតុភាព សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួល ៥០ % និងប្រាក់បន្ទាប់បន្សំឱ្យបានមុនថ្ងៃឈប់សម្រាក ។

៣- សុំឱ្យក្រុមហ៊ុនសាងសង់រោងបាយសម្រាប់កម្មករហូបបាយ ។

៤- នៅពេលក្រុមហ៊ុនបញ្ឈប់កម្មករណាម្នាក់ ក្រុមហ៊ុនត្រូវធ្វើការជូនដំណឹងឱ្យកម្មករបានដឹងមុនអំពីកំហុសរបស់ខ្លួន ។

៥- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានពេទ្យប្រចាំការ និងដាក់ថ្នាំក្នុងប្រអប់ និងសំភារៈឱ្យបានគ្រប់គ្រាន់ទៅតាមអាគារនីមួយៗ ។

៦- ចំពោះកម្មករធ្វើខុសនៅក្នុងមាត្រា ៨៣ ក្រុមហ៊ុនត្រូវធ្វើការដោះស្រាយតាមច្បាប់ស្តីពីការងារ ។

៧- សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួល និងលុយបាយដាច់ដោយឡែកពីគ្នា (ដោយកំណត់ថ្ងៃទី២៤ ជាថ្ងៃបើកលុយបាយ) ។

៨- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល និងប្រាក់រង្វាន់តាមច្បាប់ និងទូទាត់រំលឹកសារឡើងវិញ ។

៩- នៅពេលកម្មករដាក់ច្បាប់ឈប់សម្រាកសុំកុំឱ្យក្រុមហ៊ុនធ្វើការកាត់ប្រាក់ទ្រទ្រង់ជីវភាព ៦ដុល្លាឡើយ

១០- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យស្ត្រីដែលមានផ្ទៃពោះទៅពិនិត្យសុខភាព ០១ ថ្ងៃក្នុងមួយខែ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗ ។

១១- នៅពេលក្រុមហ៊ុនមិនមានការងារឱ្យកម្មកធ្វើគ្រប់គ្រាន់ ក្រុមហ៊ុនត្រូវគិតប្រាក់ឈ្នួល ១០០% ។

១២- សុំឱ្យក្រុមហ៊ុនរៀបចំបទបញ្ជាផ្ទៃក្នុង ។

១៣- ក្រុមហ៊ុនត្រូវធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ។

១៤- សុំឱ្យក្រុមហ៊ុនរៀបចំសាងសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូន និងមានអ្នកមើលថែទាំក្មេង (ព្រមទាំងសំភារៈក្មេងលេង) ។

១៥- រាល់ការបាត់បង់សំភារៈរបស់កម្មករ ក្រុមហ៊ុនត្រូវទទួលខុសត្រូវ ។

១៦- ពេលចូលឆ្នាំខ្មែរម្តងៗ សុំឱ្យក្រុមហ៊ុនជប់លៀងលើកទឹកចិត្តដល់កម្មករ ឬបើកកម្មវិធីប្រលងប្រណាំងយករង្វាន់អនុស្សាវរីយ៍ ។

១៧- នៅពេលកម្មករដាក់ច្បាប់ឈឺ ហើយមានសំបុត្រពេទ្យរដ្ឋ ក្រុមហ៊ុនមិនត្រូវកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗទេ ។

THE ARBITRATION COUNCIL

១៨- នៅពេលក្រុមហ៊ុនដាក់ PN ទៅឱ្យកម្មករធ្វើ ក្រុមហ៊ុនត្រូវបញ្ជាក់តំលៃឡូតិ៍ឱ្យកម្មករបានដឹងរយៈពេល ០៣ ថ្ងៃ ទៅមួយអាទិត្យ ។

១៩- នៅពេលកម្មករធ្វើខុសម្តងម្កាល ក្រុមហ៊ុនត្រូវធ្វើការណែនាំផ្ទាល់មាត់សិន មុននឹងឱ្យទៅធ្វើការព្រមានជាលាយល័ក្ខអក្សរ ហើយរាល់ពេលដែលព្រមាន សុំឱ្យមានការចុះហត្ថលេខាពីតំណាងសហជីព ។

២០- នៅពេលកម្មករឈប់សម្រាក ហើយសុំច្បាប់ត្រឹមត្រូវ សំណូមពរឱ្យក្រុមហ៊ុនកុំធ្វើការកាត់ប្រាក់រង្វាន់ ។

២១- នៅពេលក្រុមហ៊ុនតម្រូវឱ្យកម្មករបន្ថែមម៉ោង ពីម៉ោង ៦:០០ ទៅម៉ោង ៨:០០ សំណូមពរឱ្យក្រុមហ៊ុនផ្តល់បាយមួយពេល និងលុយក្នុងម្នាក់ ២០០០ រៀល ។

២២- សំណូមពរឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់កម្មករណាដែលធ្វើការជូនក្រុមហ៊ុនបានល្អ ។

២៣- សំណូមពរឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលកម្មករគិតជាប្រាក់ដុល្លាទាំងអស់ ។

២៤- សំណូមពរឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករដែលបានផ្តិតមេដៃ និងគោរពតាមក្រុមហ៊ុន សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យចូលធ្វើការវិញ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៣) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១៥៣/១០ កប/កណ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ : ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលបណ្តឹងចំនួន ២៤ ចំណុច របស់កម្មករនិយោជិតដែលទាមទារឱ្យក្រុមហ៊ុនធ្វើការកែលំអរលក្ខខណ្ឌការងារនៅក្នុងក្រុមហ៊ុនឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ប៉ុន្តែ មិនបានទទួលលទ្ធផលសះជាទេ លើការទាមទារចំនួន ២៤ ចំណុច ។ ចំណុចមិនសះជាចំនួន ២៤ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ២៤ ចំណុចនេះ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០ (វេលាម៉ោង ១៤:00 នាទី រសៀល) ។

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិត និងភាគីនិយោជកមិនបានចូលរួមសវនាការទេ ដោយផ្អែកទៅលើលិខិតដកពាក្យបណ្តឹងរបស់កម្មករនិយោជិតចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ ផ្ញើរជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតដកពាក្យបណ្តឹងនេះ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- **ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

ខ- **ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

- លិខិតដកពាក្យបណ្តឹងរបស់កម្មករនិយោជិត ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ ផ្ញើជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

គ- **ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ព្រែកព្រែង ត្រេឌីង លេខ ១៥៣/១០ កប/កណ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ព្រែកព្រែង ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០

៣- លិខិតពឹងពាក់ និងជួយអមរបស់កម្មករ កម្មការិនីនៃក្រុមហ៊ុន ព្រែកព្រែង ក្នុងការសម្រុះសម្រួលជាមួយក្រុមហ៊ុន-ក្រសួងការងារ-ក្រុមប្រឹក្សាអាជ្ញាកណ្តាល-តុលាការ-អាជ្ញាធរ និងស្ថាប័នគ្រប់ជាន់

THE ARBITRATION COUNCIL

ថ្នាក់ដែលពាក់ព័ន្ធ នូវករណីវិវាទការងារ ជូនលោកប្រធានសហព័ន្ធសហជីពយុវជនខ្មែរ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៧១ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៧២ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- យោងតាមលិខិតពឹងពាក់ និងជួយអមរបស់កម្មករនិយោជិតទាំអស់នៃសិប្បកម្មព្រែកត្រែង ផ្ញើជូនប្រធានសហពន្ធ័សហជីពយុវជនខ្មែរ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩ កម្មករនិយោជិតទាំងនោះបានផ្ទេរសិទ្ធិឱ្យទៅតំណាងចំនួន ១០ រូប ក្នុងការសម្របសម្រួលជាមួយក្រុមហ៊ុន-ក្រសួងការងារ-ក្រុមប្រឹក្សាអាជ្ញាកណ្តាល-តុលាការ-អាជ្ញាធរ និងស្ថាបន័គ្រប់ជាន់ថ្នាក់ដែលពាក់ពន្ធ័។ អ្នកទទួលការផ្ទេរសិទ្ធិនោះមានឈ្មោះដូចជា :១. លោក នៅ ទិត្យា ២. លោក សែម សំអឿន ៣. លោក ចាន់ សុផាន់ ៤. លោក ឃុត សុភា ៥. លោក ឃុត សុភាព ៦. អ្នកស្រី មួន ចន្ថា ៧. កញ្ញា សុក យ៉េន ៨. លោក ថេង ប៊ុនថន ៩. កញ្ញា ព្រំ សាំងគី ១០. កញ្ញា ពោន ស៊ីណាន ។
- នៅវេលាម៉ោង ៩ និង ១០ នាទី ព្រឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០ មុនម៉ោងសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលលិខិតដកពាក្យបណ្តឹងរបស់កម្មករនិយោជិតនៅសិប្បកម្មព្រែកត្រែង ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ ស្តីពីការសុំដកពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ហើយដែលត្រូវបានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានធ្វើការផ្សះផ្សានៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១០ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។
- នៅក្នុងលិខិតដកពាក្យបណ្តឹងនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានស្នាមមេដៃតំណាងឱ្យកម្មករនិយោជិតនៅសិប្បកម្មព្រែកត្រែងចំនួន ១៨ នាក់។ ក្នុងចំណោមតំណាងកម្មករនិយោជិតចំនួន ១៨ នាក់នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានឈ្មោះ៦ នាក់ ដូចជា ១. លោក ឃុត សុភា

២. លោក ឃុត សុភាព ៣. អ្នកស្រី មួន ចន្ថា ៤.លោក ថេង ប៊ុនថន ៥. កញ្ញា សុក យ៉េន ៦.កញ្ញា ព្រំ សាំងគី ដែលបានទទួលការផ្ទេរសិទ្ធិឱ្យសំរាប់ធ្វើការសម្របសម្រួលជាមួយក្រុមហ៊ុន-ក្រសួងការងារ-ក្រុមប្រឹក្សាអាជ្ញាកណ្តាល-តុលាការ-អាជ្ញាធរ និងស្ថាប័នគ្រប់ជាន់ថ្នាក់ដែលពាក់ពន្ធ័។

**ហេតុផលនៃសេចក្តីសម្រេចៈ**

យោងតាមលិខិតដកពាក្យបណ្តឹងរបស់តំណាងកម្មករនិយោជិតនៅសិប្បកម្មព្រែកព្រែង ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តំណាងកម្មករនិយោជិតទាំង ៦ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតនេះ មានសិទ្ធិធ្វើការសម្រេចទៅលើចំណុចវិវាទរបស់កម្មករនិយោជិតដែលបានផ្ទេរសិទ្ធិឱ្យខ្លួនថា តើគួរបន្តចំណុចវិវាទទាំងនេះទៀត ឬដកពាក្យបណ្តឹង។ ដូច្នេះ យោងតាមលិខិតដកពាក្យបណ្តឹងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លិខិតនេះមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការបិទសំណុំរឿងនេះ ពីព្រោះ កម្មករនិយោជិតបានបង្ហាញឆន្ទៈថា ខ្លួនចង់បញ្ចប់សំណុំរឿងនេះ ដោយធ្វើការដកពាក្យបណ្តឹង។

បន្ថែមពីនេះទៀត នៅក្នុសំណុំរឿងលេខ *៤៧/០៥- ហ៊ូ អ៊ី ហ្គាមិន* ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា " *យោងតាមលិខិតរបស់សហព័ន្ធសហជីពឯករាជ្យ និងប្រជាធិបតេយ្យ និងសហជីព មូលដ្ឋាននៃក្រុមហ៊ុន ហ៊ូ អ៊ី ហ្គាមិន ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៥ ស្តីពីការសុំបញ្ចប់សុំណុំរឿង ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាមទារបានដកការទាមទាររបស់ខ្លួនវិញ ដូច្នេះរឿងនេះ ត្រូវបញ្ចប់ជាស្វ័យប្រវត្តិ ។* "

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញដូចសំណុំរឿងខាងលើដែរ មានន័យថា កាលបើដើមបណ្តឹងបានសម្រេចចិត្តដកពាក្យបណ្តឹងហើយនោះ នាំឱ្យការទាមទារនៅក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់។

ផ្អែកលើអំណះអំណាងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចដូចខាងក្រោមៈ

**សម្រេច និង បង្គាប់**

បិទសំណុំរឿងលេខ ៣១/១០- ព្រែកព្រែង ត្រេឌីង។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៈ

ឈ្មោះ ៈ អ៊ីង សុន្ធី

ហត្ថលេខាៈ ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **សុខ វណ្ណស៊ីន**

ហត្ថលេខា: ------------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------------------